**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ**
**គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន** CFAVC
**អង្គភាពអនុវត្តគម្រោងខេត្ត** PPIU/TAK

**សូមគោរពជូន**
**លោកនាយកគម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន** CFAVC

**កម្មវត្ថុ:** ស្តីពីរបាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ២០២៣

## I.សេចក្តីផ្តើម

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន CFAVC មានគោលបំណង បង្កើនប្រាក់ចំណូលដល់ប្រជាជនតាមជនបទនិងជំរុញការប្រកួតប្រជែងនៃខ្សែច្រវាក់ផលិតកម្មកសិកម្ម ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលមានសមាសភាគសំខាន់ៗចំនួន០៣៖

- កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មឲ្យមានភាពប្រសើរឡើង ហើយធននឹងអាកាសធាតុ ដើម្បីជំរុញការប្រកួតប្រជែងខ្សែច្រវ៉ាក់ផលិតកម្មស្រូវ ពោត ដំឡូងមី និងស្វាយ ក្នុងខេត្តគោលដៅគម្រោងចំនួនបួន (កំពង់ចាម ត្បូងឃ្មុំ តាកែវ និងកំពត)
- ជំរុញការអនុវត្តកសិកម្ម និងកសិ-ធុរៈកិច្ចមានលក្ខណៈស្របទៅនឹងអាកាសធាតុ
- រៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគកសិ-ធុរៈកិច្ចប្រកបដោយភាតរៈបរិស្ថាន។

## II. ស្ថានភាពមន្ត្រី៖

| ល.រ | នាម គោត្តនាម | ភេទ | តួរនាទី | លេខទូរសព្ទ័ |
|---|---|---|---|---|
| ១ | លោក ញិប ស្រ៊ន | ប | ប្រធានអង្គភាពអនុវត្តគម្រោង PPIU | ០១២ ២៥០ ០៤១ |
| ២ | លោក លឹម ចាន់ណា | ប | មន្ត្រី | ០១២ ៤៦៤ ១៥៥ |
| ៣ | លោក សោ សារឿង | ប | មន្ត្រី | ០៩២ ៧៥១ ៧៥៧ |
| ៤ | លោកស្រី កែប សុកន | ស | មន្ត្រី | ០៩២ ១២៤ ៦៩៧ |
| ៥ | លោក ញិប សុខុម | ប | មន្ត្រី | ០១០ ៧១៩ ៩៧០ |
| ៦ | លោក យូ ងនស៊ាង | ប | មន្ត្រី | ០១២ ៣៨០ ០៣៥ |
| ៧ | លោក ហន ឧត្តម | ប | មន្ត្រី | ០៩៦ ៥៦៤ ០៣៣៣ |
| ៨ | លោកស្រី ផន បុល | ស | មន្ត្រី | ០៨៦ ៧៨៣ ៤២៧ |
| ៩ | លោកស្រី ឃឹម រតនា | ស | មន្ត្រី | ០៨៦ ២៣៤ ៣៦៧ |
| ១០ | លោក សុខ វេត | ប | មន្ត្រី | ០៨៨ ២៨១៥០០០ |

| | | | | |
|---|---|---|---|---|
| ១១ | លោក ញ៉ិប ពិសិដ្ឋ | ប | អ្នកបើកបរ | ០៨១ ៩៨៦ ២៦២ |

## II. សកម្មភាព និងលទ្ធផលសម្រេចបាន

### ក. រៀបចំការប្រជុំ រឺ ចូលរួមប្រជុំផ្សេងៗ

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ១៨.០៩.២០២៣ | ភូមិពានមាសកើត ឃុំលំពង់ ស្រុកបាទី | • បានចុះរំលឹកឡើងវិញជាមួយគណកម្មាធិការនិងសមាជិកសហគមន៍កសិកម្មលំពង់សាមគ្គី | PPIU.TAK និងកសិករ | ៤ | ០ | បានចុះរំលឹកឡើងវិញជាមួយគណកម្មាធិការនិងសមាជិកសហគមន៍កសិកម្មលំពង់សាមគ្គី នៅភូមិពានមាសកើត ឃុំលំពង់ ស្រុកបាទី ហើយបានអោយគណកម្មាធិការសហគមន៍ពិនិត្យមើលលើការងារមួយចំនួនដូចខាងក្រោម៖<br>- ត្រៀមរៀបចំរបាយការណ៍សម្រាប់បង្ហាញដល់ការចុះទស្សនៈកិច្ចរបស់ ADB<br>- រៀបចំរចនាសម្ព័ន្ធសហគមន៍<br>- ដំណើរការមុខរបរទិញ លក់ស្រូវឆ្នាំមុន និងផែនការបន្ត<br>- ការស្វែងរកទុនបន្ថែមសម្រាប់ពង្រីកមុខរបរសហគមន៍<br>- ធ្វើការសំអាតទាំងបរិវេនខាងក្នុង និងខាងក្រៅឃ្លាំងដែលបានសាងសង់រួច<br>- ស្ត្រីចូលរួមក្នុងការងារគ្រប់គ្រងដឹកនាំ<br>- រៀបចំដាំកូនឈើនៅជុំវិញឃ្លាំង |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ១៨.០៩.២០២៣ | ភូមិតាសូរ ឃុំឧត្តមសុរិយា ស្រុកត្រាំកក់ | • បានប្រជុំជាមួយគណៈកម្មការសហគមន៍កសិកម្ម និងកសិករប្រព័ន្ធកសិកម្មចម្រុះដើម្បីរៀបចំទីតាំងដែលគម្រោងបានគាំទ្រ ត្រៀមក្នុងកម្មវិធីទស្សនៈកិច្ចរបស់ម្ចាស់ជំនួយនៃគម្រោង (CFAVC) នៅសហគមន៍កសិកម្មឧត្តមសុរិយា | PPIU.TAK និងកសិករ | ៥ | ៣ | បានប្រជុំជាមួយគណៈកម្មការសហគមន៍កសិកម្ម និង កសិករប្រព័ន្ធកសិកម្មចម្រុះដើម្បីរៀបចំទីតាំងដែលគម្រោងបានគាំទ្រត្រៀមក្នុងកម្មវិធីទស្សនៈកិច្ចរបស់ម្ចាស់ជំនួយនៃគម្រោង (CFAVC) នៅសហគមន៍កសិកម្មឧត្តមសុរិយា ភូមិតាសូរ ឃុំឧត្តមសុរិយា ស្រុកត្រាំកក់ ។ អ្នកចូលរួមសរុបចំនួន20នាក់ ស្រី13នាក់។ បានបន្តចុះពិនិត្យតាមដាន និង ណែនាំពីរការប្រើប្រាស់ និង ថែទាំឡជីវឧស្ម័ន ដល់កសិករផងដែរ ។ |
| ២២.០៩.២០២៣ | ភូមិទទឹង ឃុំភ្នំដិន ស្រុកគិរីវង់ | • បានចូលរួមវគ្គបណ្តុះបណ្តាលកសិករស្តីពីការអនុវត្តការគ្រប់គ្រងល្អ លើដំណាំស្រូវនៅសហគមន៍កសិកម្មភ្នំដិនសែនសុខ | PPIU.TAK និងកសិករ | ២ | 0 | បាន ចូលរួម វគ្គ បណ្តុះបណ្តាល កសិករ ស្តី ពី ការ អនុវត្ត ការ គ្រប់គ្រង ល្អ លើ ដំណាំស្រូវ នៅ សហគមន៍ កសិកម្ម ភ្នំ ដិន សែន សុខ ភូមិទទឹង ឃុំភ្នំដិត ស្រុកគិរីវង់ មានការ សម្រប សម្រួល ដោយ គ្រូ ស៊ាង ឡៃ ហេង ប្រធាន ការិយាល័យ ក្សេត្រវិទ្យា និង ប្រព័ន្ធ កសិកម្ម នៃ វិទ្យាស្ថាន (CARDI) និង សហការ រី ។ កសិករ សរុប ចំនួន ២៥នាក់ ស្រី ០៣នាក់។ មាតិកាដូចខាងក្រោម៖ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | - លក្ខណៈរូបសាស្ត្រលើដំណាំស្រូវ<br>- ដំណាក់កាល លូតលាស់ លើ ដំណាំ ស្រូវ<br>- ការរៀបចំ ដី<br>- វិធីសាស្ត្រ នៃ ការ ដាំដុះ<br>- ការ គ្រប់គ្រង ទឹក<br>- សត្វ ល្អិត និង ការ ការពារ<br>- ជំងឺ សំខាន់ ៗ លើ ដំណាំស្រូវ និង វិធានការ គ្រប់គ្រង<br>- ការ ប្រូតកាត់ និង ការ ទុកដាក់ ។ |
| ២៦.០៩.២០២៣ | សហគមន៍កសិកម្ម លំពង់សាមគ្គី | • បានចុះជួបជាមួយគណកម្មាធិការសហគមន៍កសិកម្ម លំពង់សាមគ្គី និងអាជ្ញាធរ ឃុំលំពង់ ពិភាក្សាក្នុងការត្រៀមរៀបចំសម្រាប់ការចុះទស្សនៈកិច្ចរបស់ ADB នៅថ្ងៃទី២៩/០៩/២៣ | PPIU.TAK និងកសិករ | ៤ | ០ | ចំនួន៤នាក់/ស្រី០នាក់ បានចុះជួបជាមួយគណកម្មាធិការសហគមន៍កសិកម្ម លំពង់សាមគ្គី និងអាជ្ញាធរ ឃុំលំពង់ ពិភាក្សាក្នុងការត្រៀមរៀបចំសម្រាប់ការចុះទស្សនៈកិច្ចរបស់ ADB នៅថ្ងៃទី ២៩/០៩/២៣ ខាងមុខនេះ ។ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ០៦.១០.២០២៣ | ភូមិព្រៃភ្លូង ឃុំសំបួរ ស្រុកទ្រាំង | • បានចុះសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសផលិតគ្រាប់ពូជស្រូវនៅសហគមន៍កសិកម្មសំបួរចំរើនផល | PPIU.TAK និងកសិករ | ២ | ២ | បានចុះសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសផលិតគ្រាប់ពូជស្រូវនៅសហគមន៍កសិកម្មសំបួរចំរើនផល ស្ថិត នៅ ភូមិព្រៃភ្លូង ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ដែលមាននាក់ចូលរួមសរុប២៥នាក់ ស្រី១២នាក់។<br>ក្រោមអធិបតីភាព លោក នូ គីហេន អនុប្រធានការិយាល័យរុក្ខជម្រើសវិទូនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |

## ខ. ប្រជុំ រឺ ចូលរួមសិក្ខាសាលា

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ២០.០៩.២០២៣ | ខេត្តកែប | • បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីច្បាប់ពូជដំណាំនិងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ពូជដំណាំ (Dissemination workshop on Seed Law and Regulation under Seed Law) | PPIU.TAK និងកសិករ | ៤ | 0 | បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីច្បាប់ពូជដំណាំនិងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ពូជដំណាំ (Dissemination workshop on Seed Law and Regulation under Seed Law) នៅសណ្ឋាគារសង្គហមិត្តខេត្តកែប។ ក្រោមអធិបតី លោក តែ ចាន់តារា អនុប្រធាននាយកដ្ឋានពូជដំណាំ ដែល មាននាក់ចូលរួមសរុប២៣នាក់ ស្រី៨នាក់។ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ២០.០៩.២០២៣ | រាជធានីភ្នំពេញ | • បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធធានាគុណភាពពូជដំណាំ ប.គ.ព ក្រោមអធិបតីភាពលោក អោម ពេជ្រ ប្រធាននាយកដ្ឋានពូជដំណាំ | PPIU.TAK និងកសិករ | ២ | ២ | បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីប្រព័ន្ធធានាគុណភាពពូជដំណាំ ប.គ.ព ក្រោមអធិបតីភាពលោក អោម ពេជ្រ ប្រធាននាយកដ្ឋានពូជដំណាំ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុប ២៥ នាក់ ស្រី ០៦នាក់។ |
| ០៣.១០.២០២៣ | ខេត្តតាកែវ | • បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសគ្រប់គ្រង សមាសភាពចង្រៃលើផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី | PPIU.TAK និងកសិករ | ៣ | ៣ | មន្ត្រីគម្រោងចំនួន ០៣ រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសគ្រប់គ្រង សមាសភាពចង្រៃលើផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី ដែលមានរយៈពេល ៣ថ្ងៃចាប់ពីថ្ងៃទី០២-០៤/ ០៩/២០២៣ នៅសណ្ឋាគារអាលីសវីឡា ទីរួមខេត្តតាកែវ មានអ្នកចូលរួម ២៧ ស្រី ១២នាក់។ |
| ០៣.១០.២០២៣ | ខេត្តកែប | • បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹកគ្រូបង្គោល ស្តីពី ការប្រើប្រាស់និង ថែទាំគ្រឿងយន្តកសិកម្ម | PPIU.TAK និងកសិករ | ៣ | ០ | បានចូលរួមវគ្គបណ្តុះបណ្តាលរំលឹកគ្រូបង្គោលស្តីពីៈ ការប្រើប្រាស់និង ថែទាំគ្រឿងយន្តកសិកម្ម វគ្គបណ្តុះបណ្តាលនេះស្ថិតនៅក្រោមធិបតីភាពលោក សេង សារ៉ាត់ ទីប្រឹក្សាក្រសួងកសិកម្ម ហើយធ្វើនៅសណ្ឋាគារសង្គហមិត្ត ខេត្តកែប មានអ្នកចូលរួមសរុប១២នាក់/ស្រី០១នាក់។ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ០៤.១០.២០២៣ | ខេត្តកំពត | • បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំសៀវភៅមគ្គុទ្ទេសក៍ និងការចុះបញ្ជី ISO 17025 | PPIU.TAK | ១ | 0 | បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំសៀវភៅមគ្គុទ្ទេសក៍ និងការចុះបញ្ជី ISO 17025 រៀបចំដោយមន្ទីរពិសោធន៍ថ្នាក់ជាតិ មានរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី ៤-៥/១០/២៣ នៅសណ្ឋាគារកំពតស្ទីតបូទិច ទីរួមខេត្តកំពត<br>អ្នកចូលរួមសរុប ២០នាក់/ស្រី៧នាក់ ។ |
| ០៤.១០.២០២៣ | ខេត្តកំពត | • បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើពាណិជ្ជកម្មនិងទីផ្សារលើផលិតផល និង សេវាកម្មចេញពីមន្ទីរ ពិសោធន៍ | PPIU.TAK និងសហគមន៍ | ៣ | 0 | បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើពាណិជ្ជកម្មនិងទីផ្សារលើផលិតផល និង សេវាកម្មចេញពីមន្ទីរ ពិសោធន៍ ដោយ សម្របសម្រួល ដោយ លោក បណ្ឌិត រឿន ស៊ីវ៉ាណេត ទីប្រឹក្សា ផ្នែកផែនការអាជីវកម្មមន្ទីរពិសោធន៍នៃគម្រោង CFAVC និង សហការី ។ វគ្គបណ្តុះបណ្តាលធ្វើឡើងនៅសណ្ឋាគារកំពត ស្វីតប៊ូទិក ខេត្តកំពត ។ |
| ០៩.១០.២០២៣ | ខេត្តកំពង់ចាម | • បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តកសិកម្មល្អកម្ពុជាលើដំណាំស្វាយ | PPIU.TAK | ៦ | ៣ | បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអនុវត្តកសិកម្មល្អកម្ពុជាលើដំណាំស្វាយ វគ្គបណ្តុះបណ្តាលនេះស្ថិតក្រោមអធិបតីភាព លោក មាន ចេតនា ប្រធានការិយាល័យលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងលោកភួង |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផល |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | តារាអនុប្រធានទីប្រឹក្សាCS2ដែលមានរយៈពេល ៣ថ្ងៃចាប់ពីថ្ងៃទី០៩-១១/ ១០/២០២៣ នៅសណ្ឋាគារភ្នំប្រុស ទីរួមខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន ១៦ នាក់ស្រី ០៦នាក់។ |

## គ.ការត្រួតពិនិត្យ តាមដានការងារធ្វើបង្ហាញ/ការសាកសង់ រឺ ការងារផ្សេងៗពាក់ពន្ធ័

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ១៦.០៩.២០២៣ | ១-សហគមន៍កសិកម្មសាមគ្គីមានជ័យ<br>២-សហគមន៍កសិកម្មមាន់ស្រែអូរផុត | • បានចុះពិនិត្យមើលស្ថានភាពលូតលាស់និងដកពូជលាយស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវពូជផ្ការំដួលចំនួន ២បង្ហាញ | PPIU.TAK និងកសិករ | ២ | ២ | បានចុះពិនិត្យមើលស្ថានភាពលូតលាស់ និងដកពូជលាយស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវពូជ ក្នុងសហគមន៍កសិកម្មសាមគ្គីមានជ័យ ភូមិព្រៃក្តួច ឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ដែលមានដូចខាងក្រោម៖<br>○ កសិករ ធឿន ចិន្តា ភេទស្រី<br>○ ផ្ទៃដី ចំនួន ៖៣០០០ ម៉ែត្រការ៉េ<br>○ ឈ្មោះពូជ ៖ផ្ការំដួល<br>○ ផ្តល់បច្ចេកទេសបាចជីបំប៉នលើកទី២<br>○ វគ្គលូតលាស់(ដំណាក់កាលពន្លូតដើម) |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ ស្រូវដុះលូតលាស់ល្អ<br>○ មានទឹកគ្រប់គ្រាន់<br>○ គ្មានការបំផ្លាញពីសត្វល្អិតនិងជំងឺ<br>○ មិនមានបញ្ហាជួបប្រទះ<br>សហគមន៍កសិកម្មមាន់ស្រែអូរផុត ភូមិអូរផុត ឃុំអង្គតាសោម ស្រុកត្រាំកក់<br>○ កសិករ កន ភារម្យ ភេទស្រី<br>○ ផ្ទៃដី ចំនួន ៖៣០០០ ម៉ែត្រការ៉េ<br>○ ឈ្មោះពូជ ៖ផ្ការំដួល<br>○ ផ្តល់បច្ចេកទេសបាចជីបំប៉នលើកទី២<br>○ វគ្គលូតលាស់ (ដំណាក់កាលពន្លូតដើម)<br>○ ស្រូវដុះលូតលាស់ល្អ<br>○ មានទឹកគ្រប់គ្រាន់<br>○ គ្មានការបំផ្លាញពីសត្វល្អិត និងជំងឺ<br>○ បញ្ហាជួបប្រទះមានស្មៅដុះតិចតួច |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ ដំណោះស្រាយ សុំអោយម្ចាស់ស្រែដកសំអាតស្មៅអោយបានស្អាត និងពិនិត្យស្រែអោយបានទៀងទាត់។ |
| ១៦.០៩.២០២៣ | កសិកម្មចំប៉ាព្រៃផ្តៅ | • បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវចំប៉ីស៧០ នៅសហគមន៍ កសិកម្មចំប៉ាព្រៃផ្តៅ | PPIU.TAK និងកសិករ | ២ | 0 | បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវចំប៉ីស៧០ នៅសហគមន៍ កសិកម្ម ចំប៉ាព្រៃផ្តៅ នៅភូមិសំរោង ឃុំចំប៉ា ស្រុកព្រៃកប្បាស ទទួលបានលទ្ធផលដូចខាងក្រោម ៖<br>○ ស្រែកសិករ ទូន សុប៉េង ភេទប្រុស<br>○ មានផ្ទៃដី ១៥០០ម៉ែត្រការ៉េ<br>○ ដំណាក់កាលចេញ កួរនិងចេញផ្កា<br>○ ធ្វើការកាត់ពូជលាយ<br>○ មានទឹកគ្រប់គ្រាន់<br>○ ចេញស្រុះគ្នាល្អ<br>○ បញ្ហាជួបប្រទះ មានដុះពូជលាយតិចតួច និងមានស្មៅដុះតិចតួច<br>○ ដំណោះស្រាយ អោយកសិករច្រូតចេញ |
| ១៦.០៩.២០២៣ | ភូមិអង្គបក្សី. ឃុំជាងទង ស្រុកត្រាំកក់ | • បានចុះពិនិត្យមើលស្ថានភាពលូតលាស់និងដកពូជលាយស្រែ | PPIU.TAK និងកសិករ | ២ | ២ | បានចុះពិនិត្យមើលស្ថានភាពលូតលាស់ និងដកពូជលាយស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវពូជដូចខាងក្រោម៖ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | បង្ហាញផលិតកម្មគ្រាប់ស្រូវពូជផ្ការំដួល | | | | ○ សហគមន៍កសិកម្មបក្សីរីករាយនៅភូមិអង្គបក្សី. ឃុំជាងទង ស្រុកត្រាំកក់<br>○ កសិករអ៊ូ មុំ ភេទស្រី<br>○ ផ្ទៃដីចំនួន៖ ៥០០០ ម៉ែត្រការ៉េ<br>○ ឈ្មោះពូជ៖ ផ្ការំដួល<br>○ ផ្តល់បច្ចេកទេសបាចជីបំប៉នលើកទី២<br>○ វគ្គលូតលាស់(ដំណាក់កាលពន្លូតដើម)<br>○ ស្រូវដុះលូតលាស់ល្អ<br>○ មានទឹកគ្រប់គ្រាន់<br>○ គ្មានការបំផ្លាញពីសត្វល្អិតនិងជំងឺ<br>○ មិនមានបញ្ហាជួបប្រទះ |
| ១៩.០៩.២០២៣ | ភូមិតាំងរាសី ឃុំព្រៃខ្លា ស្រុកកោះអណ្តែត | • បានចុះស្ទង់ស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវទៅតាមលក្ខណៈបច្ចេកទេស នៅសហគមន៍កសិកម្មសំភ្លីអង្គររង្សី | PPIU.TAK និងកសិករ | ២ | ០ | បានចុះស្ទង់ស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវទៅតាមលក្ខណៈបច្ចេកទេស នៅសហគមន៍កសិកម្មសំភ្លីអង្គររង្សីនៅភូមិតាំងរាសី ឃុំព្រៃខ្លា ស្រុកកោះអណ្តែត រួម មានដូច ខាងក្រោម ៖<br>○ កសិករឈ្មោះ៖ ស៊ីវ សុផល ភេទស្រី |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ ផ្ទៃដី ចំនួន ៖៣០០០ម៉ែត្រការ៉េ<br>○ ឈ្មោះពូជ ៖ ខា១៦<br>○ សាប ៖ ២៨-០៨-២០២៣<br>○ ថ្ងៃស្ទូង ៖១៩-០៩-២០២៣<br>○ ចន្លោះស្ទូង៖ 20cmx20cm<br>○ ការប្រើជីទ្រាប់បាត<br>○ ជីដេអា បេចំនួន៖ ១៥kg<br>○ ជីប៉ូតាស្យូមចំនួន៖ ៧,៥kg<br>○ ជីអ៊ុយរ៉េ ៖ ៣ kg<br>○ កសិករចូលរួម ៩នាក់/ ស្រី០៦នាក់ |
| ២០.០៩.២០២៣ | ភូមិអង្គក្តី ឃុំសឹង្ហ ស្រុកសំរោង | • បានចុះពិនិត្យស្រែបង្ហាញ ផលិតកម្មពូជស្រូវផ្ការំដួល នៅ សហគមន៍កសិកម្មនិទានសំរោង | PPIU.TAK និងកសិករ | ២ | ២ | បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវ ផ្ការំដួល នៅ សហគមន៍ កសិកម្មនិទានសំរោង នៅភូមិអង្គក្តី ឃុំសឹង្ហ ស្រុកសំរោង ទទួលបានលទ្ធផលដូចខាងក្រោម ៖<br>○ ស្រែបង្ហាញកសិករ ធី លីម ភេទប្រុស<br>○ មានផ្ទៃដី ៣០០០ម៉ែត្រការ៉េ<br>○ វគ្គលូតលាស់(ដំណាក់កាល ពន្លកដើម) |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ ធ្វើការដកពូជលាយ<br>○ ស្រែមានទឹកគ្រប់គ្រាន់<br>○ សន្ទូងលូតលាស់ល្អ<br>○ បញ្ហាជួបប្រទះ មានដុះពូជលាយតិចតួច និងមានស្មៅដុះតិចតួច<br>○ ដំណោះស្រាយ អោយកសិករច្រូតចេញ |
| ២២.០៩.២០២៣ | ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ | • បានចុះពិនិត្យមើលស្ថានភាពលូលាស់និងដកពូជលាយស្រែបង្ហាផលិតកម្មគ្រាប់ស្រូវពូជផ្កាមាលតី | PPIU.TAK និងកសិករ | ២ | ២ | បានចុះពិនិត្យមើលស្ថានភាពលូតលាស់ និងដកពូជលាយស្រែបង្ហាញផលិតកម្មគ្រាប់ស្រូវពូជដូចខាងក្រោម៖<br>○ សហគមន៍កសិកម្មដំរីរមៀល ភូមិត្រពាំងឈូក ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់<br>○ កសិករ សុខ សុខន ភេទស្រី<br>○ ផ្ទៃដីចំនួន ៖៣០០០ ម៉ែត្រការ៉េ<br>○ ឈ្មោះពូជ ៖ផ្កាមាលតី<br>○ ផ្តល់បច្ចេកទេសបន្សុតពូជ និងដកពូជលាយ<br>○ វគ្គលូតលាស់(ដំណាក់កាលពន្លូតដើម)<br>○ ស្រូវដុះលូតលាស់ល្អ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ មានទឹកគ្រប់គ្រាន់<br>○ គ្មានការបំផ្លាញពីសត្វល្អិត និងជំងឺ<br>○ មិនមានបញ្ហាជួបប្រទះ |
| ២៦.០៩.២០២៣ | សហគមន៍កសិកម្មឧត្តមសុរិយា ស្រុកត្រាំកក់ | • បានចុះកម្មសិក្សាស្តីពីការប្រមូលសំណាកជីកសិកម្មជីវសាស្ត្រ និងជីសរីរាង្គនៅផ្សារធំតាកែវ | PPIU.TAK និងកសិករ | ២ | 0 | បានចូលរួមជាមួយ លោក យ៉ាង សុខហេង អនុប្រធានមន្ទីរពិសោធន៍ ជាតិកសិកម្ម លោក ម៉ាក់ ចន្ទរតនា ទីប្រឹក្សាបច្ចេកទេសគម្រោង CFAVC ផ្នែក ជីកសិកម្មជីវសាស្ត្រ និងជីសរីរាង្គ ព្រមទាំងសហការី ដើម្បីចុះកម្មសិក្សាស្តីពីការប្រមូលសំណាកជីកសិកម្មជីវសាស្ត្រ និង ជី សរីរាង្គនៅផ្សារធំតាកែវ និងពេលរសៀលបន្តចុះមើលជីសរីរាង្គ នៅសហគមន៍កសិកម្មឧត្តមសុរិយា ស្រុកត្រាំកក់ ។ |
| ០២.១០.២០២៣ | ភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង | • បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវ ផ្កាមាលតី នៅACពន្លឺកសិករ | PPIU.TAK និងកសិករ | ២ | 0 | បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវ ផ្កាមាលតី នៅACពន្លឺកសិករ នៅភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ទទួលបានលទ្ធផលដូចខាងក្រោម ៖<br>○ ស្រែកសិករ តឹប ណៃ ភេទស្រី<br>○ ផ្ទៃដី 2400ម៉ែត្រការេ<br>○ បាចជីបំប៉នលើកទី1 ថ្ងៃទី20/09/23 |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| | | | | | | ○ សន្ទុងមានការលូតលាស់ និងបែកគុម្ពល្អ<br>○ កាត់ពូជលាយ<br>○ មិនមានបញ្ហាជួបប្រទះទេ |
| ០៥.១០.២០២៣ | ភូមិអង្គបក្សី ឃុំជាងទង ស្រុកត្រាំកក់ | • បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវផ្ការំដួលនៅ AC បក្សីរីករាយ | PPIU.TAK និងកសិករ | ២ | ២ | បានចុះពិនិត្យស្រែបង្ហាញផលិតកម្មពូជស្រូវផ្ការំដួលនៅAC បក្សីរីករាយភូមិអង្គបក្សីឃុំជាងទងស្រុកត្រាំកក់។ទទួលបានលទ្ធផលដូចខាងក្រោម ៖<br>○ ស្រែកសិករ អ៊ូ មុំ ភេទស្រី<br>○ ផ្ទៃដី 5000ម៉ែត្រការ៉េ<br>○ បាចជីបំប៉នលើកទី2នៅ ថ្ងៃទី15/09/23<br>○ មានការលូតលាស់ កំលាំលូតលាស់ខ្លាំង<br>○ ដំណាក់កាលផើម<br>○ កាត់ពូជលាយ<br>○ បញ្ហាជួបប្រទះ<br>○ មិនមានបញ្ហាទេ<br>○ ផែនការបន្ត<br>○ ធ្វើការកាត់ពូជលាយ |

| ថ្ងៃទី | ទីកន្លែង | បរិយាយសកម្មភាព | អ្នកចូលរួម | ចំនួនអ្នកចូលរួម(នាក់) | | លទ្ធផលទទួលបាន |
|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | |
| ០៩.១០.២០២៣ | ឃុំចំប៉ា ស្រុកព្រៃកប្បាស | • បានចុះវាស់ស្ទង់ទិន្នផលស្រែបង្ហាញផលិតកម្មពូជស្រូវ ចំប៉ីស៧០ ចំនួន០១បង្ហាញដោយច្រូតយកចំនួន៥សំណាកផ្សេងៗគ្នា | PPIU.TAK និងកសិករ | ២ | ០ | បានចុះវាស់ស្ទង់ទិន្នផលស្រែបង្ហាញផលិតកម្មពូជស្រូវ ចំប៉ីស៧០ ចំនួន០១បង្ហាញ ដោយច្រូតយកចំនួន ៥សំណាកផ្សេងៗគ្នា (១សំណាក=១ម៉ែត្រការ៉េ) ទទួលបានលទ្ធផលដូចខាងក្រោម៖<br>○ កសិករ ទួន សុប៉េង ភេទប្រុស<br>○ ផ្ទៃដីដាំដុះ ១៥០០ម៉ែត្រការ៉េ<br>○ ពូជស្រូវ ចំប៉ីស៧០<br>នៅសហគមន៍កសិកម្ម ចំប៉ាព្រៃផ្ដៅ ឃុំចំប៉ា ស្រុកព្រៃកប្បាសទទួលបានលទ្ធផលដូចខាងក្រោម៖<br>○ សំណាកទី ១ = 0,៤0kg<br>○ សំណាកទី ២ = 0,៤៣kg<br>○ សំណាកទី ៣ = 0,៤៧Kg<br>○ សំណាកទី ៤ = 0,៤៥kg<br>○ សំណាកទី ៥= 0,៤៥kg<br>○ កាត់សំណើម ២0%<br>○ ទិន្នផលជាមធ្យមសរុបគិតក្នុងមួយហិកតា = ៤១00Kg |

III. **ផលលំបាក/បញ្ហាជួបប្រទះ សកម្មភាពខាងលើ**

- មានស្មៅដុះច្រើនក្នុងស្រែ (ផលិតកម្មពូជស្រូវ)
- មានដង្កូវស៊ីរូងដើមតិចតួច (ផលិតកម្មពូជស្រូវ)
- មានការកាត់បំផ្លាញតិចតួចដោយសត្វកណ្តុរ (ផលិតកម្មពូជស្រូវ)

IV.**ដំណោះស្រាយ:**

- ឲ្យកសិករបន្តចុះពិនិត្យស្រែបានជាប្រចាំ(ដកស្មៅ,កាត់ពូជលាយដើមស្រូវខ្ពស់ឬទាបជាងចេញ) (ផលិតកម្មពូជ)
- ត្រូវរក្សាទឹកទុកក្នុងស្រែឲ្យបានពី៥-១០សង់ទីម៉ែត្រជាកាល្អ(ផលិតកម្មពូជ)
- ត្រូវបន្ថយទឹកនិងបង្ហូរទឹកឲ្យអស់ដំណាក់កាលស្រូវទុំ(ផលិតកម្មពូជ)

V. **សំណូមពរ**

- គម្រោងជួយពន្លឿនការសាងសង់ឡជីវឧស្ម័ន និង រោងជីកំប៉ុស្តិ៍សំរាប់ការធ្វើបង្ហាញ និងជាវដោយអតិថិជន

VI. **សន្និដ្ឋាន**

ជារួមក្នុងខែកញ្ញា ឆ្នាំ២០២៣ អង្គភាពអនុវត្តគម្រោងខេត្ត PPIU បានខិតខំយកចិត្តទុកដាក់អនុវត្តសកម្មភាពតាមផែនការរបស់គម្រោងក្នុងនោះរួមមានៈ

**១. ផ្នែកអភិវឌ្ឍន៍គោលនយោបាយ ស្តង់ដា និងពូជធន់នឹងការប្រែប្រួលអាកាសធាតុ**

បានចុះពិនិត្យ និងប្រគល់ពូជសម្រាប់ធ្វើផលិតកម្មដំណាំស្រូវចំនួន២៣បង្ហាញរួមមាន៖

- ស្រុកត្រាំកក់១១បង្ហាញ
- ស្រុកទ្រាំង៣បង្ហាញ
- ស្រុកសំរោង៤បង្ហាញ
- ស្រុកគិរីវង់២បង្ហាញ
- ស្រុកព្រៃកប្បាស២បង្ហាញ
- ស្រុកកោះអណ្តែត១បង្ហាញ

មន្ត្រីអង្គភាពអនុវត្តគម្រោងបានចុះផ្តល់បច្ចេកទេសការប្រើប្រាស់ជីបំប៉នលើកទី២ដល់កសិករបង្ហាញផលិតកម្មពូជស្រូវផ្កាមាលតីចំនួន៥បង្ហាញក្នុង៤សហគមន៍កសិកម្មរួមមាន

- សហគមន៍ដំរីរមៀលក្នុងស្រុកត្រាំកក់១បង្ហាញ
- សហគមន៍បឹងអមតៈនិងសហគមន៍ពន្លឺកសិករស្ថិតក្នុងស្រុកសំរោង២បង្ហាញ
- សហគមន៍សំបួរចម្រើនផលស្ថិតក្នុងស្រុកទ្រាំង១បង្ហាញ
- សហគមន៍អង្គប្រាសាទសុខសែនជ័យស្ថិតក្នុងស្រុកគិរីវង់១បង្ហាញ

មន្ត្រីអង្គភាពអនុវត្តគម្រោងបានចុះផ្តល់បច្ចេកទេសស្ទូងដល់កសិករបង្ហាញផលិតកម្មពូជស្រូវផ្ការំដួលចំនួន១បង្ហាញក្នុង១សហគមន៍រួមមាន

- សហគមន៍កសិកម្មសាមគ្គីមានជ័យ ស្ថិតក្នុងស្រុកត្រាំកក់

មន្ត្រីអង្គភាពអនុវត្តគម្រោងបានចុះផ្តល់បច្ចេកទេសការប្រើប្រាស់ជីបំប៉នលើកទី២ដល់កសិករបង្ហាញផលិតកម្មពូជស្រូវផ្ការំដួលចំនួន១១បង្ហាញក្នុង១១សហគមន៍រួមមាន៖

- សហគមន៍មាន់ស្រែអូរផុត សហគមន៍សុខភាពយើង សហគមន៍ខ្ពបស្វាយសាមគ្គី សហគមន៍សែនសុខ ទឹកថ្លា សហគមន៍ភូមិបីសាមគ្គី សហគមន៍ត្រពាំងក្រញូងនិងសហគមន៍បក្សីរីករាយស្ថិតក្នុងស្រុកត្រាំកក់
- សហគមន៍និទានសំរោងនិងសហគមន៍ស្វាយរន្ធអមតៈស្ថិតក្នុងស្រុកសំរោង
- សហគមន៍មរតករុងរឿងនិងសហគមន៍សំបូរចម្រើនផលស្ថិតក្នុងស្រុកទ្រាំង

មន្ត្រីអង្គភាពអនុវត្តគម្រោងបានចុះវាស់ស្ទង់ទិន្នផលស្រែបង្ហាញផលិតកម្មពូជស្រូវចាប៉ីស៧០ចំនួន២បង្ហាញ២ សហគមន៍សិកម្មរួមមានៈ

- សហគមន៍ចំប៉ាព្រៃផ្តៅស្រុកព្រៃកប្បាស ទិន្នផលជាមធ្យមសរុបគិតក្នុង ១ហិកតា=៤១០០គីឡូក្រាម
- សហគមន៍ទួលព្រះវិហារស្រុកព្រៃកប្បាស ទិន្នផលជាមធ្យមសរុបគិតក្នុង១ហិចតា= ៥០៥៨គីឡូក្រាម

ខា១៦ ចំនួន៤បង្ហាញ (ដំណាក់កាលទុំ)៖

- សហគមន៍សំភ្លីរង្សីនិងសហគមន៍ពន្លឺសរីវាង្គស្ថិតក្នុងស្រុកកោះអណ្តែត
- សហគមន៍ភ្នំជិនសែនសុខស្ថិតក្នុងស្រុកគិរីវង់
- សហគមន៍បក្សីរីករាយស្ថិតក្នុង ស្រុកត្រាំកក់

## ២. ផ្នែកគ្រឿងយន្តកសិកម្ម

ចុះពិនិត្យការដ្ឋានសាងសង់ឃ្លាំងស្តុកស្រូវពូជនិងចំណីចំនួន០៥កន្លែងរួមមានៈ

- សហគមន៍កសិកម្មសុខភាពយើង
  - ✓ ការដ្ឋានសាងសង់សម្រេចបានប្រហែលពី៧៨-៨០ភាគរយ
  - ✓ បានណែនាំដល់ក្រុមជាងពីសុវត្ថិភាពក្នុងការសាងសង់និងបរិស្ថានបានពន្យល់ដល់ក្រុមជាងសុវត្ថិភាពក្នុងការសាងសង់
- សហគមន៍ខ្ពបស្វាយសាមគ្គី
  - ✓ ការដ្ឋានសាងសង់សម្រេចបានប្រហែលពី៧៨-៨០ភាគរយ
  - ✓ បានណែនាំដល់ក្រុមជាងពីសុវត្ថិភាពក្នុងការសាងសង់និងបរិស្ថានបានពន្យល់ដល់ក្រុមជាងសុវត្ថិភាពក្នុងការសាងសង់
- សហគមន៍កសិកម្មសាមគ្គីមានជ័យផ្លូវលោក
  - ✓ ការដ្ឋានសាងសង់សម្រេចបានប្រហែលពី៧៨-៨០ភាគរយ
  - ✓ បានណែនាំដល់ក្រុមជាងពីសុវត្ថិភាពក្នុងការសាងសង់និងបរិស្ថានបានពន្យល់ដល់ក្រុមជាងសុវត្ថិភាពក្នុងការសាងសង់
- សហគមន៍កសិកម្មឧត្តមសុរិយា
  - ✓ ការដ្ឋានសាងសង់សម្រេចបានប្រហែលពី៧៨-៨០ភាគរយ
  - ✓ បានណែនាំដល់ក្រុមជាងពីសុវត្ថិភាពក្នុងការសាងសង់និងបរិស្ថានបានពន្យល់ដល់ក្រុមជាងសុវត្ថិភាពក្នុងការសាងសង់
- សហគមន៍កសិកម្មលំពង់សាមគ្គី
  - ✓ ការដ្ឋានសាងសង់រួច១០០ភាគរយ

បានរួមដំណើរជាមួយទីប្រឹក្សាបច្ចេកទេសCS1បានជួបពិភាក្សាជាមួយសមាជិកក្រុមប្រឹក្សាឃុំមេភូមិត្រពាំងក្រញូងនិងតំណាងគណៈកម្មាធិការសហគមន៍កសិកម្មក្នុងគោលបំណងដើម្បីពិនិត្យទីកន្លែងនិងការរៀបចំឯកសារសម្រាប់សហគន៍កសិកម្មទាំង៧សហគមន៍មានដូចជា:

1. សហគមន៍កសិកម្មសាមគ្គីខ្ពបស្វាយ
2. សហគមន៍កសិកម្មត្រពាំងក្រញូង
3. សហគមន៍កសិកម្មសាមគ្គីមានជ័យ
4. សហគមន៏កសិកម្មស្តុកស្តម្ភ
5. សហគមន៏កសិកម្មលំពង់សាមគ្គី
6. សហគមន៏កសិកម្មត្រពាំងក្រឡាញ់
7. សហគមន៏កសិកម្មឧត្តមសុរិយា

**៣. បានទទួលទស្សនៈកិច្ចក្រុមបេសកកម្មវាយតម្លៃពាក់កណ្តាលគម្រោង (MTR)៖**

ពិនិត្យប្រពន្ធ័ធារាសាស្ត្ររួមមានទំនប់ទឹកព្រៃក្តួច និង ប្រឡាយទឹកក្រាំងអំពិល ក្នុងឃុំត្រពាំងក្រញូង ស្រុកត្រាំកក់

រៀបចំកិច្ចប្រជុំបង្ហាញពីផែនការអនុវត្ត និងលើកទិសដៅបន្ត នៅមន្ទីរ

ពិនិត្យអគារបណ្តុះបណ្តាលរបស់គម្រោងបានសាងសង់រួចរាល់

ពិនិត្យសកម្មភាពឡជីវឧស្ម័ន និងរោងជីកំប៉ុស្តិ៍ និងឃ្លាំងស្តុកស្រូវចំណី នៅសហគមន៍កសិកម្មឧត្តមសូរិយា ស្រុកត្រាំកក់។

ពិនិត្យឃ្លាំងស្តុកស្រូវចំណី និងប្រជុំពិភាក្សា នៅសហគមន៍កសិកម្មលំពង់សាមគ្គី ស្រុកបាទី

**៤. ប្រជុំផ្សេងៗ**

ប្រជុំបូកសរុបប្រចាំខែកញ្ញា និងលើកផែនការបន្ត

## VII. ផែនការបន្ត

ប្រជុំវឌ្ឍនភាពប្រចាំខែ ចំនួន ០១ប្រជុំ

បន្តតាមដានការសាងសង់ឃ្លាំងស្រូវចំនួន ១១ ឃ្លាំង

បើកវគ្គបណ្តុះបណ្តាលកសិកម្មផលិតកម្មដំណាំស្រូវប្រកបដោយនិរន្តរភាព (SRP)

បើកវគ្គបណ្តុះបណ្តាលកសិកម្មវៃឆ្លាតធន់ទៅនិងអាកាសធាតុ (CSA)

បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់និងថែទាំគ្រឿងយន្តកសិកម្ម

បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីឡជីវឧស្ម័ន និង ជីឡឧស្ម័នដល់អ្នកផ្សព្វផ្សាយឃុំ,ស្រុក

បើកវគ្គបណ្តុះបណ្តាលផលិតជីកំប៉ុស្តិ៍ និងការប្រើប្រាស់ ដល់កសិករនិងសហគមន៏កសិកម្ម

ការចុះបង្វឹកណែនាំតាមសហគមន៍ស្តីពីការផ្សព្វផ្សាយ និងទីផ្សារឡជីវឧស្ម័ននិងរោងជីកំប៉ុស្តិ៍

ការប្រជុំក្រុមតូចតាមភូមិ ដើម្បីផ្សព្វផ្សាយនិងស្វែងរកអ្នកស្ម័គ្រចិត្តជាវឡជីវឧស្ម័ន និងរោងជីកំប៉ុស្តិ៍

ថ្ងៃ ព្រហស្បតិ៍ ១៣រោច ខែ ភទ្របទ ឆ្នាំថោះបញ្ចស័ក ព.ស ២៥៦៧

តាកែវ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០២៣

**ប្រធានអង្គភាពអនុវត្តគម្រោង** PPIU